ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

-សំណុំរឿងរដ្ឋប្បវេណីលេខ ១២០ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២០។
-សាលក្រមលេខ: ០៧ "ខ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០។

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តតាកែវ

បង្កើតឡើងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកត/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

បានបើក នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ដោយមានសមាសភាពដូចតទៅ៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

-ដើមចោទឈ្មោះ [redacted] ស្រីនាង ភេទស្រី អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបររកស៊ី កម្មការនីរោងចក្រ ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] សុខ (រស់) ម្តាយ ឈ្មោះ [redacted] ស៊ីម៉ុន (រស់) ប្តីឈ្មោះ [redacted] ប្រុសតន់ (រស់) មានកូន គ្មាន ដោយមានលោក [redacted] និងលោក [redacted] ជាសហមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ [redacted] ប្រុសតន់ ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបររកស៊ី ប៉ះកង់ឡាន ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ ផុន (រស់) ម្តាយឈ្មោះ អុល (រស់) ប្តីឈ្មោះ [redacted] ស្រីនាង (រស់) មានកូនគ្មាន ។

## ១.អង្គហេតុ និង ចំណុចវិវាទ ៖

ក.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ៖

-សុំលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ប្រុសតន់ ។

## ២.ការពន្យល់ត្រួសៗអំពីរឿងក្តី ៖

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ស្រីនាង ជាដើមចោទ បានបញ្ជាក់ថា៖ ខ្លួន និងចុងចម្លើយឈ្មោះ [redacted] ប្រុសតន់ បានរៀបការជាមួយគ្នាជាប្តី-ប្រពន្ធ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ប៉ុន្តែ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ។ ក្រោយពេលរៀបការ ខ្លួន និងចុងចម្លើយ ពុំមានកូននោះទេ ដោយសារចុងចម្លើយអសមត្ថភាពផ្លូវភេទ មិនអាចបន្តពូជបាន។



Scanned with CamScanner

ការរស់នៅជាមួយគ្នា ចេះតែមិនចុះសម្រុងនឹងគ្នា មិនតែប៉ុណ្ណោះចុងចម្លើយ បានចុះចោលខ្លួន កាលពីថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២០ ដោយគ្មានមូលហេតុ ដែលជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនា ពុំអាចទ្រាំរស់ទៅជាមួយចុងចម្លើយតទៅទៀតបាន។ ការរស់នៅជាមួយគ្នាកន្លងមក ខ្លួននិងចុងចម្លើយ ពុំមានទ្រព្យសម្បត្តិរួម និងបំណុលនោះទេ។

**៣.ចំណុចវិវាទ៖**

-ដើមចោទនូវតែរក្សាការប្តឹងទាមទារដូចមានក្នុងពាក្យបណ្តឹងរបស់ខ្លួនដដែល។

-ចុងចម្លើយទាមទារប្រាក់ចំនួន១.០០០.០០០រៀល (មួយលាន)រៀល។

**៤.សេចក្តីថ្លែងការណ៍និងការអះអាងរបស់គូភាគី ៖**

-ដើមចោទឈ្មោះ [redacted] ស្រីនាង បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួននៅតែរក្សាការប្តឹងសុំលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ប្រុសតន់ ដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ នោះដដែល។ ដោយហេតុថាៈ ខ្លួន និងចុងចម្លើយឈ្មោះ [redacted] ប្រុសតន់ បានរៀបការជាមួយគ្នាជាប្តី-ប្រពន្ធ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ប៉ុន្តែ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ។ ក្រោយពេលរៀបការ ខ្លួន និងចុងចម្លើយ ពុំមានកូននោះទេ ដោយសារចុងចម្លើយអសមត្ថភាពផ្លូវភេទ មិនអាចបន្តពូជបាន។ ការរស់នៅជាមួយគ្នាកន្លងមក ចេះតែមិនចុះសម្រុងនឹងគ្នា ដោយចុងចម្លើយ បានចុះចោលខ្លួន តាំងពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ មករហូត ដោយគ្មានមូលហេតុ ដែលជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនា ពុំអាចទ្រាំរស់ទៅជាមួយចុងចម្លើយតទៅទៀតបាន។ ខ្លួន និងចុងចម្លើយ ពុំមានទ្រព្យសម្បត្តិរួម និងបំណុល ដែលពាក់ព័ន្ធនឹងគ្នាទៀតទេ។ ដោយឡែកប្រាក់ចំនួន១.០០.០០០រៀល (មួយលាន)រៀល ដែលចុងចម្លើយបានទាមទារនោះ ជាប្រាក់ខែរបស់ខ្លួន ដោយខ្លួនបានចាត់ចែងអស់ហើយ នៅពេលដែលខ្លួនបានរស់នៅជាមួយចុងចម្លើយ និងនៅពេលដែលចុងចម្លើយបានចុះចោលខ្លួននោះ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់ថាៈ ខ្លួនឯកភាពតាមការថ្លែងការណ៍របស់កូនក្តីខ្លួន ដោយខ្លួនសុំបន្ថែមថា កូនក្តីខ្លួនមានហេតុផលសមរម្យក្នុងការលែងលះជាមួយនឹងចុងចម្លើយ ហើយចំពោះប្រាក់មួយលានរៀលនេះ មានមែន ប៉ុន្តែ ជាប្រាក់ខែដែលកូនក្តីខ្លួនបានធ្វើការងាររោងចក្រ ហើយក៏បានចាត់ចែងអស់ហើយ នៅពេលដែលបានរស់នៅជាមួយចុងចម្លើយ និងនៅពេលដែលចុងចម្លើយបានចុះចោលនោះ។ ចុងចម្លើយ បានថ្លែងការណ៍ឯកភាពនូវការលែងលះពីកូនក្តីខ្លួន រីឯការថ្លែងការណ៍ត្រង់ប្រាក់មួយលានរៀល ឃើញថា ពុំមានហេតុផល ឬមានមូលដ្ឋានត្រឹមត្រូវនោះទេ ហេតុនេះ ខ្លួនស្នើសុំតុលាការពិចារណានូវការថ្លែងរបស់កូនក្តីខ្លួនខាងលើ ដោយស្នើសុំតម្កល់ពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ និងច្រានចោលនូវការទាមទារប្រាក់ចំនួន ១.០០០.០០០រៀល (មួយលាន)រៀល របស់ចុងចម្លើយ។



Scanned with CamScanner

-ចុងចម្លើយឈ្មោះ [redacted] ប្រុសតន់ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនឯកភាពលែងលះជាមួយដើមចោទ ហើយខ្លួនពិតជាបានរៀបការជាមួយដើមចោទ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ និងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ពិតមែន ចំពោះកូន គឺខ្លួន និងដើមចោទ ពុំមានទេ រីឯទ្រព្យសម្បត្តិរួម ទ្រព្យសម្បត្តិដោយឡែក និងបំណុល គឺ ខ្លួន និងដើមចោទ ពុំមានជាប់ពាក់នឹងគ្នាទៀតទេ បានធ្វើការបែងចែកគ្នានៅចំពោះមុខអាជ្ញាធរភូមិឃុំ រួចហើយ តែខ្លួននៅមិនទាន់បានទទួលប្រាក់ចំនួនមួយលានរៀល ដែលដើមចោទថាប្រគល់មកឱ្យខ្លួននៅឡើយ។ ខ្លួនពិតជាអសមត្ថភាពផ្លូវភេទ និងបានចុះចេញផ្ទះដូចការលើកឡើយរបស់ដើមចោទពិតមែន។ ចំពោះប្រាក់មួយលានរៀននេះ ជាប្រាក់រកស៊ីជាមួយគ្នាហើយក៏ជាប្រាក់ខែរបស់ដើមចោទធ្វើការងាររោងចក្រផងដែរ ព្រោះដើមចោទថា ប្រគល់ប្រាក់នេះមកឱ្យខ្លួន។ ប្រាក់ដែលខ្លួនរកបានៗធ្វើការបែងចែកអស់ហើយ ចំណែកប្រាក់របស់ដើមចោទមិនបានបែងចែកនោះទេ។

-សាក្សីឈ្មោះ [redacted] ស៊ីម៉ុន បានបញ្ជាក់ថា៖ ចំពោះប្រាក់ដែលឈ្មោះ [redacted] ប្រុសតន់ ទាមទារពីកូនរបស់ខ្លួននេះ គឺពុំពិតឡើយ ដោយប្រាក់នេះ កូនខ្លួនបានបែងចែកជាមួយនឹងឈ្មោះនេះ រួចអស់ហើយនៅចំពោះមុខអាជ្ញាធរភូមិឃុំ ដោយឈ្មោះនេះ ក៏ទទួលបានរួចហើយដែរ ចំណែកប្រាក់ដែលនៅសល់ពីការបែកគ្នានោះ គឺជាប្រាក់ខែរបស់កូនខ្លួននោះទេ ដោយមិនមានជាប់ពាក់ព័ន្ធនឹងគ្នាទៀតទេ។

## សំអាងហេតុ៖

១-តាមការបញ្ជាក់របស់គូភាគីខាងលើ ឃើញថា គូភាគីពិតជាបានរៀបការជាមួយគ្នាជាប្តី-ប្រពន្ធ ហើយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ពិតប្រាកដមែន។

២-ក្រោយពេលរៀបអាពាហ៍ពិពាហ៍ គូភាគីពិតជារស់នៅមិនចុះសម្រុងនឹងគ្នា ដោយមូលហេតុ ភាគីចុងចម្លើយអសមត្ថភាពផ្លូវភេទ និងបានបែកលំនៅឋានពីគ្នា តាំងពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ មកដល់សព្វថ្ងៃ ដែលជាហេតុធ្វើឱ្យគូភាគីអស់មនោសញ្ចេតនាក្នុងការរួមរស់នៅជាមួយគ្នាតទៅទៀតបាន ហើយគូភាគីបានព្រមព្រៀងគ្នា លែងលះពីគ្នា ពិតប្រាកដមែន។ ហេតុនេះ តុលាការគប្បីទទួលស្គាល់នូវការព្រមព្រៀងរបស់គូភាគី តាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី។

៣-ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍នឹងគ្នា ដើមចោទ និងចុងចម្លើយ ពុំមានកូន និងទ្រព្យសម្បត្តិរួម ទ្រព្យសម្បត្តិដោយឡែក និងបំណុល នោះទេ ហេតុនេះ គប្បីតុលាការពុំធ្វើការពិចារណាលើចំណុចទាំងនេះឡើយ។

៤-ចុងចម្លើយបានប្តឹងសុំទាមទារប្រាក់ចំនួន ១.០០០.០០០រៀល (មួយលាន)រៀល ពីដើមចោទ ឃើញថា ពុំមានលក្ខណៈសមហេតុផល អាចឱ្យតុលាការពិចារណាបានឡើយ ដោយហេតុថា ប្រាក់នេះដើមចោទបានបញ្ជាក់ថាមានពិតមែន ប៉ុន្តែ ខ្លួនបានចាត់ចែងអស់ហើយ នៅពេលដែលរស់នៅជាមួយចុង



Scanned with CamScanner

ចម្លើយ និងនៅពេលដែលចុងចម្លើយបានចុះចោលខ្លួននោះ ហើយប្រាក់នេះក៏ជាប្រាក់ខែរបស់ខ្លួនផងដែរ។ សេចក្តីថ្លែងការណ៍របស់ដើមចោទ មានភាពស្របគ្នាផងដែរ ជាមួយនឹងការបញ្ជាក់របស់សាក្សីឈ្មោះ [redacted] ស៊ីម៉ុន ដែលបានបញ្ជាក់ថា៖ ប្រាក់ដែលឈ្មោះ [redacted] ប្រុសតន់ ទាមទារពីកូនរបស់ខ្លួន គឺពុំពិតឡើយ ដោយប្រាក់នេះ បានបែងចែកគ្នារួចអស់ហើយនៅចំពោះមុខអាជ្ញាធរភូមិឃុំ ដោយឈ្មោះនេះ ក៏ទទួលបានរួចហើយដែរ ចំណែកប្រាក់ដែលនៅសល់ពីការបែកគ្នានោះ គឺជាប្រាក់ខែរបស់កូនខ្លួននោះទេ ដោយមិនមានជាប់ពាក់ព័ន្ធនឹងគ្នាទៀតទេ។ការទាមទាររបស់ចុងចម្លើយ និងការបញ្ជាក់របស់សាក្សីនូវប្រាក់ចំនួន ១.០០០.០០០រៀល (មួយលាន)រៀលនេះ គប្បីតុលាការច្រានចោលការទាមទាររបស់ចុងចម្លើយ។

៥-តាមការបញ្ជាក់របស់គូភាគីខាងលើ ឃើញថា ភាគីចុងចម្លើយបានអសមត្ថភាពផ្លូវភេទមិនអាចបន្តពូជបាន និងបានបែកលំនៅឋានពីគ្នា តាំងពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ មកដល់សព្វថ្ងៃ ហេតុនេះ គប្បីតុលាការពុំពិចារណាអំពីការកំណត់ភាពមេម៉ាយរបស់ភាគីដើមចោទនោះឡើយ។

៦-ប្រាក់ប្រដាប់ក្តី យោងតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីជាបន្ទុករបស់ដើមចោទ។

**សេចក្តីសម្រេចចុងក្រោយ ៖**

**១**.ឱ្យដើមចោទឈ្មោះ [redacted] **ស្រីនាង** និងចុងចម្លើយឈ្មោះ [redacted] **ប្រុសតន់** លែងលះពីគ្នាចាប់ពីពេលនេះតទៅ។

**២**.ច្រានចោលការទាមទារប្រាក់ចំនួន១.០០០.០០០រៀល (មួយលាន)រៀល របស់ចុងចម្លើយ។

**៣**.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះ បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខដើមចោទ និងចុងចម្លើយ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និង ត្រា** [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ១១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

តាកែវ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner